ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានព័ត៌មាន និងឯកសារ

# សេចក្ដីជូនព័ត៌មាន

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ**កម្ពុជា** និងឯកឧត្ដម **ថងលូន ស៊ីស៊ូលីត** (Thongloun SISOULITH) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត**ឡាវ** នឹងអញ្ជើញធ្វើជាអធិបតីរួមគ្នាក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ រវាងព្រះរាជាណាចក្រ**កម្ពុជា** (ច្រកត្រពាំងក្រៀល - ខេត្តស្ទឹងត្រែង) និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត**ឡាវ** (ច្រកណុងណុកខៀន- ខេត្តចម្ប៉ាសាក់) នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧។

**សម្ដេចតេជោ ហ៊ុន សែន** និងឯកឧត្ដម **ថងលូន ស៊ីស៊ូលីត** នឹងថ្លែងសុន្ទរកថាក្នុងពិធីសម្ពោធបន្ទាប់មកនឹងអញ្ជើញកាត់ខ្សែបូរដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារទីស្នាក់ការត្រួតពិនិត្យនេះ។

បន្ទាប់ពីពិធីសម្ពោធ **សម្ដេចតេជោ ហ៊ុន សែន** នឹងអញ្ជើញទៅទស្សនាទំនប់វារីអគ្គីសនីដនសាហុង ដែលមានទីតាំងនៅក្នុងខេត្តចម្ប៉ាសាក់។

ឥស្សរជនជាន់ខ្ពស់កម្ពុជាជាច្រើនរូបទៀត នឹងអមដំណើរសម្ដេចតេជោ ហ៊ុន សែន ក្នុងពិធីសម្ពោធដ៏សំខាន់នេះ ដូចជា៖

| | |
|---|---|
| ១. ឯកឧត្ដម **ហោ ណាំហុង** | ឧបនាយករដ្ឋមន្ត្រី |
| ២. លោកជំទាវ **ម៉ែន សំអន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច |
| ៣. ឯកឧត្ដម **កែ គីមយ៉ាន** | ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| ៤.ឯកឧត្ដម **ប្រាក់ សុខុន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង |

សមាជិកជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ផ្សេងទៀត។

អាសយដ្ឋាន៖ លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ការបើកឲ្យប្រើប្រាស់ច្រកទ្វារត្រួតពិនិត្យព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវថ្មីនេះ បង្ហាញពីការរីកចំរើនថ្មីមួយក្នុងទំនាក់ទំនងទ្វេភាគី រវាងប្រទេសទាំងពីរ។ ការបើកឲ្យប្រើប្រាស់នេះ ក៏នឹងឆ្លើយតបផងដែរចំពោះតម្រូវការពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ ព្រមទាំងជួយសម្រួលបន្ថែមទៀតដល់ពាណិជ្ជកម្មតាមព្រំដែន ទេសចរណ៍ និងការតភ្ជាប់រវាងប្រទេសទាំងពីរ។

ភ្នំពេញ, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៧